**ការណ៍ពិតអំពីវ៉ាក់សាំង**

# សំណួរដែលចោទសួរញឹកញាប់ អំពីថ្នាំ COVID-19 ចាក់បន្ថែម

តើអ្នកមានសំណួរ អំពីថ្នាំ COVID-19 ចាក់បន្ថែម ឬទេ?
រកចំឡើយរបស់អ្នក ខាងក្រោម និងទស្សនា mass.gov/CovidVaccine



**តើហេតុអ្វីខ្ញុំ ត្រូវការថ្នាំ COVID ចាក់បន្ថែម?**

វ៉ាក់សាំង COVID-19 គឺមានប្រសិទ្ធិភាពខ្ពស់ ប៉ុន្តែក៏ដូចវ៉ាក់សាំងជាច្រើនទៀតដែរ ថ្នាំចាក់បន្ថែម គឺត្រូវការ ដើម្បីឲ្យប្រាកដថាបានការពារជាទីបំផុត នៅពេលយូរៗទៅ។ ថ្នាំ COVID-19 ចាក់បន្ថែម ផ្តល់ការការពារថែមទៀត មកពីវីរុស និងពូជវីរុសបំផ្លែងខ្លួនរបស់វា។ ការចាក់ថ្នាំបន្ថែម បង្កើនសមត្ថភាព របស់អ្នក ដើម្បីតតាំងនឹងវីរុស។

**តើមានថ្នាំចាក់បន្ថែម ណាមួយ?**

ឥឡូវនេះមាន ថ្នាំចាក់បន្ថែម Pfizer, Moderna, និង Johnson & Johnson។ វាទាំងអស់សុទ្ធតែមាន សុខសុវត្ថិ ឥតគិតថ្លៃ និងមានប្រសិទ្ធិភាព។

**តើខ្ញុំត្រូវយកអ្វីមកជាមួយខ្ញុំ ដើម្បីទៅចាក់ថ្នាំបន្ថែម?**

អ្នកមិនបាច់ត្រូវការ ID ឬការធានាសុខភាព ឬក៏ប័ណ្ណវ៉ាក់សាំង ដើម្បីចាក់ថ្នាំ COVID បន្ថែមឡើយ។ តែយ៉ាងណាមិញ ការមានប័ណ្ណធានាសុខភាពរបស់អ្នក និងប័ណ្ណវ៉ាក់សាំង COVID-19 អាចជាជំនួយខ្លាំង ដើម្បីធ្វើឲ្យការមកជួបរបស់អ្នក ឆាប់រហ័សបំផុត។

**តើវាដល់ពេលសំរាប់ខ្ញុំ ដើម្បីខ្ញុំ ចាក់ថ្នាំបន្ថែម ឬនៅ?**

ថ្នាំចាក់បន្ថែម ផ្តល់ការការពារជាទីបំផុត ប្រឆាំងជំងឺ COVID-19 និងគ្រប់ៗគ្នាដែលមានសិទ្ធិទទួល គួរតែចាក់ថ្នាំបន្ថែមរបស់គេ។ អ្នកមានសិទ្ធិទទួលថ្នាំចាក់បន្ថែម បើសិនអ្នកអាយុ 18+ ឆ្នាំ ហើយវាបានកន្លងផុត 6 ខែ ចាប់តាំងពីដូសទីពីរ របស់អ្នក នៃថ្នាំ Moderna ឬបើសិនអ្នកអាយុ 16+ ឆ្នាំ ហើយវាបានកន្លងផុត 6 ខែ ចាប់តាំងពីដូសទីពីរ របស់អ្នក នៃថ្នាំ Pfizer ឬ 2 ខែ ចាប់តាំងពីមួយដូស នៃថ្នាំ Johnson & Johnson។

**តើខ្ញុំគួរតែជ្រើសយក ថ្នាំចាក់បន្ថែមណាមួយ?**

ថ្នាំចាក់បន្ថែមទាំងអស់ គឺមានប្រសិទ្ធិភាព និងបានយោងលើ ឱវាទេសនៃ CDC និង FDA ហើយក៏អាចចាក់លាយគ្នាបាន។ បើសិនអ្នកមានសំណួរ អំពីថ្នាំចាក់បន្ថែមរបស់អ្នក ពិគ្រោះជាមួយអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក។

ស្វែងយល់ថែមទៀត នៅ៖
**mass.gov/CovidVaccine**

វ៉ាក់សាំង សង្គ្រោះ ជីវិត

Khmer IM332